១២.១



# សិទ្ធិមានសេរីភាព

## និយមន័យ

សិទ្ធិមានសេរីភាព គឺជាសិទ្ធិមនុស្សដ៏សំខាន់របស់បុគ្គលម្នាក់ៗក្នុងការទទួលបានសេរីភាពរួចផុតពីការឃុំខ្លួន មានន័យថា មិនត្រូវដកហូតសេរីភាពក្នុងការដើរហើរតាមអំពើចិត្ត។



ការដកហូតសេរីភាព អាចកើតឡើងនៅក្នុងបរិបទជាច្រើន។ ការដកហូតសេរីភាពក្នុងបរិបទនៃបទល្មើសព្រហ្មទណ្ឌជាទូទៅរួមមានការឃាត់ខ្លួន ការឃុំខ្លួនបណ្តោះអាសន្ន ការដាប់ពន្ធនាគារបន្ទាប់ពីចោទប្រកាន់ ឬការឃុំខ្លួននៅក្នុងផ្ទះ។ ការដកហូតសេរីភាពនេះ ក៏រួមមាន ការរឹតត្បិតបន្ថែមទៅលើបុគ្គលដែលស្ថិតនៅក្រោមការឃុំខ្លួនរួចហើយ ដូចជា ការបង្ខាំងទុកឱ្យនៅដាច់ពីគេ ឬការប្រើប្រាស់ឧបករណ៍រឹតត្បិតទៅលើរូបរាងកាយ (ឧ. ខ្នោះដៃ ច្រវាក់)។ ការដកហូតសេរីភាព សំដៅដល់ការមិនមានការឯកភាព។ បុគ្គលដែលត្រូវបានសង្ស័យ ឬចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ដែលត្រូវបានឃាត់ខ្លួន និងស្ថិតនៅក្នុងការឃាត់ខ្លួន ឬឃុំខ្លួនបណ្តោះអាសន្នត្រូវបានដកហូតសេរីភាព។

ជាវិធានទូទៅ ដើម្បីការពារសិទ្ធិមានសេរីភាព បុគ្គលដែលត្រូវបានសង្ស័យ ឬចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ មិនគួរត្រូវបានដកហូតសេរីភាពដោយការរង់ចាំការជំនុំជម្រះនោះទេ។

## ក្របខ័ណ្ឌច្បាប់

### ច្បាប់អន្តរជាតិ

សិទ្ធិមានសេរីភាព ត្រូវបានការពារដោយមាត្រា ៩ (១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ "ជនគ្រប់រូបមានសិទ្ធិមានសេរីភាពនិងសន្តិសុខផ្ទាល់ខ្លួន។គ្មានជនណាម្នាក់ត្រូវចាប់ខ្លួន ឬឃុំខ្លួនតាមអំពើចិត្តបានឡើយ...[...]"។ សិទ្ធិនេះក៏មានចែងផងដែរនៅក្នុងមាត្រា៣ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។



### ច្បាប់ជាតិ




សិទ្ធិមានសេរីភាពត្រូវបានការពារដោយមាត្រា ៣២នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា"ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន [...]" ហើយមាត្រា៣៨នៃរដ្ឋធម្មនុញ្ញនេះដ៏ដែលក៏បានការពារសិទ្ធិមានសេរីភាពនេះផងដែរ។បទប្បញ្ញត្តិមួយចំនួនទៀតនៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាក៏ធានាសិទ្ធិនេះ និងបានកំណត់វិធានសម្រាប់ការឃុំខ្លួនបុគ្គលក្នុងបរិបទនៃដំណើរការនីតិវិធីព្រហ្មទណ្ឌ។

# សារសំខាន់



ជាទូទៅសិទ្ធិមានសេរីភាពរបស់បុគ្គលម្នាក់ៗ គឺជាសិទ្ធិដ៏សំខាន់ទាំងសម្រាប់បុគ្គល និងសង្គមទាំងមូល ដោយសារតែការដកហូតសេរីភាព ជាទម្លាប់បានក្លាយទៅជាមធ្យោបាយសំខាន់ក្នុងការកំណត់ការអនុវត្តសិទ្ធិសេរីភាពរបស់អ្នកដទៃទៀត។



នៅក្នុងបរិបទព្រហ្មទណ្ឌ សិទ្ធិមានសេរីភាព គឺជាសិទ្ធិដ៏សំខាន់ដើម្បីការពារការសន្មតទុកជាមុនថាគ្មានទោសរបស់ជនត្រូវចោទ ដែលជាមូលដ្ឋាននៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ត្រូវបានចាត់ទុកថាគ្មានទោសចំពោះការចោទប្រកាន់លើពួកគេ រហូតទាល់តែពិរុទ្ធភាពត្រូវបានរកឃើញតាមច្បាប់ និងត្រូវបានតុលាការផ្តន្ទាទោសជាស្ថាពរ ដូច្នេះពួកគេបន្តទទួលបានសិទ្ធិមានសេរីភាពដូចនឹងបុគ្គលផ្សេងទៀតដែរ។

# ដែនកំណត់



សិទ្ធិមានសេរីភាព គឺមិនមែនជាសិទ្ធិដាច់ខាតនោះទេ។ ច្បាប់សិទ្ធិមនុស្សអន្តរជាតិអនុញ្ញាតឱ្យមានការដកហូតសេរីភាពរបស់បុគ្គលនៅក្នុងការអនុវត្តច្បាប់ព្រហ្មទណ្ឌ។ ប៉ុន្តែ ការឃាត់ខ្លួន ឬការឃុំខ្លួនរបស់បុគ្គលចំពោះបទល្មើសព្រហ្មទណ្ឌមិនត្រូវធ្វើឡើងតាមអំពើចិត្តនោះទេ។ ឧទាហរណ៍ អាចជាការធ្វើឡើងដោយសារតែការឃុំខ្លួននេះមិនត្រឹមត្រូវ មិនយុត្តិធម៌ មិនមានមូលហេតុ មិនចាំបាច់ ឬមិនសមមាត្រ។ ការឃាត់ខ្លួន ឬការឃុំខ្លួនត្រូវធ្វើឡើងដោយស្របច្បាប់ផងដែរ។ ឧទាហរណ៍ អាចជាការអនុវត្តតាមនីតិវិធីដែលកំណត់ដោយច្បាប់ និងគោរពនីតិរដ្ឋ។



ការដកហូតសេរីភាពដោយការឃុំខ្លួនបណ្ដោះអាសន្នត្រូវតែជាករណីលើកលែង និងមិនមែនជាវិធានការចាំបាច់នោះទេ ដូច្នេះគឺត្រូវផ្អែកលើការពិនិត្យយ៉ាងត្រឹមត្រូវទៅលើបុគ្គលដែលថាត្រូវឃុំខ្លួននោះ និងចាំបាច់ដែរឬទេ ដោយពិចារណាអំពីកត្តាដែលមានបញ្ជាក់យ៉ាងច្បាស់នៅក្នុងច្បាប់ (ដូចជា ការបញ្ចៀសនៃការរត់គេចទៅបរទេស ការធ្វើឱ្យប៉ះពាល់ដល់ភស្តុតាង)។



អ្នកដែលត្រូវបានដកហូតសេរីភាពតាមរយៈការឃាត់ខ្លួន ឬឃុំខ្លួនអាចតវ៉ាតាមច្បាប់ពីការដកហូតសិទ្ធិសេរីភាពនេះ នៅចំពោះមុខតុលាការ ហើយជនរងគ្រោះពីការឃាត់ខ្លួន ឬឃុំខ្លួនខុសច្បាប់ ឬតាមអំពើចិត្តមានសិទ្ធិស្នើសុំទាមទារសំណង។

ជាចុងក្រោយ ទោះបីសិទ្ធិមានសេរីភាពត្រូវបានធានាដោយមាត្រា ៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលមិនស្ថិតនៅក្នុងបញ្ជីនៃសិទ្ធិដែលអនុញ្ញាតឱ្យមានការធ្វើបដិប្បញ្ញត្តិ*ក្នុងមាត្រា ៤ (ចំណុច ២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ការធានាប្រឆាំងនឹងការឃុំខ្លួនតាមទំនើងចិត្តមានដែលចែងក្នុងមាត្រា ៩ មិនអាចធ្វើបដិប្បញ្ញត្តិ ទោះក្នុងប្រទេសស្ថិតក្នុងគ្រាអាសន្នក៏ដោយ។

*សិទ្ធិមិនអាចធ្វើបដិប្បញ្ញត្តិ ជាសិទ្ធិដែលការអនុវត្តនូវសិទ្ធិនេះមិនអាចព្យួរដោយរដ្ឋាភិបាលទេនៅក្នុងស្ថានភាពនៃ "រដ្ឋស្ថិតនៅក្នុងគ្រាអាសន្ន"នៅក្នុងមាត្រា ៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

ខែកញ្ញា ឆ្នាំ២០២២

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

Sweden Sverige

People Change the World Diakonia

CC BY NC SA